# ព្រះរាជក្រម

នស/រកម/១១១៣/០១៥

# យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង
# ឆ្នាំ ២០១៤

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១

# ថវិកាថ្នាក់ជាតិ

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតសម្រាប់ឆ្នាំ២០១៤ឲ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដារ ភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសម្រេចនូវឧបត្ថម្ភកធនវិនិយោគ និងការខ្ចីតាមមាតិកាថវិកាដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ១៣ ៦៦៥ ៦២៧ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ៖

- ចំណូលចរន្ត.................................................................៩ ៧១២ ៦២៧ លានរៀល
- ចំណូលមូលធន...........................................................៣ ៩៥៣ ០០០ លានរៀល
    - + ចំណូលមូលធនក្នុងប្រទេស..........................................២៣៣ ០០០ លានរៀល
    - + ចំណូលមូលធនក្រៅប្រទេស.......................................៣ ៧២០ ០០០ លានរៀល
        - \- មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ.. ២៦០ ០០០ លានរៀល
        - \- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស......៣ ៤៦០ ០០០ លានរៀល

**មាត្រា ២.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ត្រូវបានកំណត់ស្មើនឹង ១៣ ៥៩៥ ៦២៧ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ៖

- ចំណាយចរន្ត.................................................................៨ ២៦៨ ៧០៣ លានរៀល
- ចំណាយមូលធន...........................................................៥ ៣២៦ ៩២៤ លានរៀល

ក-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស.....១ ៥៣៦ ០០០ លានរៀល

- \- ដោយថវិកាថ្នាក់ជាតិ..............................................១ ២៦៦ ០០០ លានរៀល
    - ▪ គម្រោងវិនិយោគផ្ទាល់.........................................១ ០០២ ០០០ លានរៀល
    - ▪ បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស....២៦៤ ០០០ លានរៀល
- \- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ......២៧០ ០០០ លានរៀល

ខ-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស....៣ ៤៦០ ០០០ លានរៀល

គ-ការទូទាត់ការខ្ចី..................................................................៣៣០ ៩២៤ លានរៀល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ត្រូវបានកំណត់ស្មើនឹង ៨ ២៦៨ ៧០៣ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៤.–**

ចំនួនទឹកប្រាក់នៃឥណទានមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០១៤ ដល់ ២០១៦ ត្រូវបានកំណត់ស្មើនឹង ១៤ ៤៥០ ០៣៨ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ តាមគម្រោងនិងតាមឆ្នាំ ដូចមានចែងក្នុងតារាង "គ១" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.–**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យានិងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ត្រូវបានកំណត់ដូចខាងក្រោម៖

- ឥណទានភ្ជាប់សន្យា.......................................................៥ ៥៩៩ ៦១៤ លានរៀល
- ឥណទានទូទាត់............................................................៥ ៣២៦ ៩២៤ លានរៀល

ឥណទាននេះត្រូវបានបែងចែកដូចតទៅ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា........................................១ ៥៣៦ ០០០ លានរៀល
- ឥណទានទូទាត់.............................................១ ៥៣៦ ០០០ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា.......................................៣ ៧៣២ ៦៩០ លានរៀល
- ឥណទានទូទាត់.............................................៣ ៤៦០ ០០០ លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា............................................៣៣០ ៩២៤ លានរៀល
- ឥណទានទូទាត់...................................................៣៣០ ៩២៤ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗនិងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដូចមានចែងក្នុងតារាង "គ២" និង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៦.–**

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ដែលបានរៀបចំនៅក្នុងតារាង "ក" ស្ដីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "ខ" ស្ដីពីចំណាយថវិកាថ្នាក់ជាតិ ត្រូវបានបង្ហាញនៅក្នុងតារាងតុល្យប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ឯកតា:លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ ហិរញ្ញប្បទាន |
|---|---|---|
| I. ចំណូលក្នុងប្រទេស | ៩ ៩៤៥ ៦២៧ | |
| ១. ចំណូលចរន្ត | ៩ ៧១២ ៦២៧ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ២៣៣ ០០០ | |
| II. សរុបចំណាយថវិកា | ១៣ ២៦៤ ៧០៣ | |
| ១. ចំណាយចរន្ត | ៨ ២៦៨ ៧០៣ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី) | ៤ ៩៩៦ ០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១ ៥៣៦ ០០០ | |
| + ដោយថវិកាថ្នាក់ជាតិ | ១ ២៦៦ ០០០ | |
| - គម្រោងវិនិយោគផ្ទាល់ | ១ ០០២ ០០០ | |
| - បដិភាគ | ២៦៤ ០០០ | |
| + ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | ២៧០ ០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៤៦០ ០០០ | |
| អតិរេកនៃថវិកាចរន្ត (I.១-II.១) | | +១ ៤៤៣ ៩២៤ |
| ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II) | | -៣ ៣១៩ ០៧៦ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +៣ ៣១៩ ០៧៦ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +៣ ៣៨៩ ០៧៦ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +២៦០ ០០០ |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | +៣ ៤៦០ ០០០ |
| • ការទូទាត់ការខ្ចី | | -៣៣០ ៩២៤ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | -៧០ ០០០ |
| • បញ្ញើរាជរដ្ឋាភិបាល | | -៨០ ០០០ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +១០ ០០០ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL